# ករណីដែលបានរាយការណ៍ស្តីពីការរំលោភបំពានផ្លូវភេទ
# នៅកម្ពុជាក្នុងឆមាសទី១ដើមឆ្នាំ២០១០

តាមច្បាប់របស់កម្ពុជា ការរំលោភបំពានផ្លូវភេទគឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរដែលជនសង្ស័យអាចត្រូវជាប់ពន្ធនាគាររហូតដល់២០ឆ្នាំ ក៏ដូចជាពិន័យជាប្រាក់ និងពលកម្មដោយបង្ខំផងដែរ។ របាយការណ៍បង្ហាញពីច្បាប់នេះកំពុងត្រូវបានអនុវត្តដោយប្រសិទ្ធិភាពយ៉ាងណានៅក្នុងប្រទេសកម្ពុជា។

អ៊ិកផាតកម្ពុជាបានធ្វើការដកស្រង់ករណីរំលោភបំពានផ្លូវភេទពីសារព័ត៌មានក្នុងស្រុកចំនួន៥គឺ កោះសន្តិភាព រស្មីកម្ពុជា កម្ពុជាថ្មី ឌឹខេមបូឌាដេលី និងភ្នំពេញប៉ុស្ត៍។ ការវិភាគនេះបង្ហាញថា មានករណីរំលោភសេពសន្ថវៈសរុប១៣៩ករណី ដែលបានរាយការណ៍នៅក្នុងរយៈពេល៦ខែដើមឆ្នាំ២០១០នេះ។ តួលេខបានបង្ហាញនូវការថយចុះ១៣ករណី បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០៩ (ថយចុះ៨,៦%)។ ទីកន្លែងដែលមានករណីកើតឡើងច្រើនបំផុតគឺ ខេត្តបាត់ដំបង រាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ចាម។ ក្នុងករណីទាំង១៣៩ បានបណ្តាលឱ្យមានជនរងគ្រោះសរុប១៤៥នាក់ (១៤៤នាក់ជាស្ត្រី និងម្នាក់ជាបុរស) ដែលជនរងគ្រោះទាំងនោះមានសញ្ជាតិជាខ្មែរ វៀតណាម ឬខ្មែរម៉ូស្លីម។ ជនរងគ្រោះចំនួន ៨៦នាក់(៥៨,៦%) មាន១៤៥នាក់ជាអនីតិជន អ្នកក្មេងបំផុតមាន អាយុ៣ឆ្នាំ។ ក្នុងចំណោមជនរងគ្រោះទាំង៨៦នាក់ ៥៨នាក់(៦៧,៤%)មានអាយុក្រោម១៥ឆ្នាំ។ ចំនួនជនរងគ្រោះសរុប និងចំនួនជនរងគ្រោះជាអនីតិជនទំនងជាថយចុះបន្តិច បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០៩ (ពី១៥៨នាក់ មក១៤៥នាក់ និងពី៩៦នាក់មក៨៥នាក់)។ មាន១៨ករណី ទាំងជនរងគ្រោះ និងជនសង្ស័យគឺជាអនីតិជនដូចគ្នា។

មានជនសង្ស័យសរុប១៨៤នាក់ពាក់ព័ន្ធក្នុងករណីរំលោភសេពសន្ថវៈទាំងនេះ (១៨៣នាក់ជាបុរស និងម្នាក់ជាស្ត្រី)។ ជនសង្ស័យមានសញ្ជាតិជាខ្មែរ វៀតណាម ឬខ្មែរម៉ូស្លីម។ ជនរងគ្រោះភាគច្រើន (៩៧,២%) និងជនសង្ស័យ (៩៦,៧%)ជាជនជាតិខ្មែរ។ បើក្រឡេកមើលទំនាក់ទំនងរវាងជនសង្ស័យ និងជនរងគ្រោះជាអនីតិជន យើងឃើញថា ចំនួន១៣ករណីមានពាក់ព័ន្ធនឹងឪពុកបង្កើត ឬឪពុកចុង ចំនួន៨ករណីមានពាក់ព័ន្ធនឹងសាច់ញាតិបង្កើត ឬសាច់ថ្លៃផ្សេងៗទៀត ចំនួន២០ករណីជាអ្នកស្គាល់គ្នា និង៤៥ករណីជាអ្នកជិតខាង ឬអ្នកភូមិជាមួយគ្នា។ ករណីភាគច្រើនបានកើតឡើងខណៈដែលជនរងគ្រោះនៅម្នាក់ឯង កំពុងគេង ចេញទៅក្រៅនៅពេលយប់ ឬទៅណាតែ ម្នាក់ឯងជាមួយជនសង្ស័យ។ លទ្ធផលបញ្ជាក់ថា យ៉ាងហោចណាស់៣១% នៃករណីទាំងអស់ត្រូវបានគ្រោងទុកជា មុន ១៣%បានពាក់ព័ន្ធនឹងគ្រឿងស្រវឹង និង៣%បានពាក់ព័ន្ធនឹងរូបភាពអាសអាភាស។ ឧប្បត្តិហេតុការរំលោភ បូកបានកើនឡើងទាំងចំនួនករណី (១៦ករណីក្នុង២០០៩ មក២១ករណី) និងចំនួនជនសង្ស័យក្នុងករណីនីមួយៗ (ចំនួនច្រើនបំផុត៩នាក់ក្នុងឆ្នាំ២០១០ ប្រៀបធៀបនឹងឆ្នាំ២០០៩មាន៧នាក់)។ ជនរងគ្រោះសរុប១៣នាក់ត្រូវបានសម្លាប់ បន្ទាប់ពីរំលោភសេពសន្ថវៈ។

ជនសង្ស័យ១៣៧នាក់ត្រូវបានចាប់ខ្លួន ៤៣នាក់បានគេចខ្លួន និង៣នាក់មិនត្រូវបានចាប់ខ្លួន។ ក្នុងពេលនៃការវិភាគនេះ ៩២ករណីបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ និង២៨ករណីស្ថិតនៅក្រោម ការស៊ើបអង្កេតបន្ថែមរបស់ប៉ូលីស។ ២ករណីត្រូវបានរាយការណ៍ថាបានដោះស្រាយក្រៅប្រព័ន្ធតុលាការ មាន២ករណីជនសង្ស័យត្រូវបានដោះលែងឱ្យនៅក្រៅឃុំ និង២ករណីក្លាយជាបណ្ដឹងរដ្ឋប្បវេណីដោយសារជនសង្ស័យមានអាយុក្រោម១៥ឆ្នាំ។ រហូតមកទល់ពេលនេះ មានតែជនសង្ស័យម្នាក់ប៉ុណ្ណោះត្រូវបានកាត់ទោស និងផ្ដន្ទាទោសពីបទរួមភេទជាមួយអនីតិជន។ ការផ្ដន្ទាទោសនោះគឺត្រូវជាប់ពន្ធនាគារ៥ឆ្នាំ និងបង្គាប់ឱ្យសងជម្ងឺចិត្តទៅជនរងគ្រោះចំនួន១២៥០$។ កង្វះខាតនៃការអនុត្តន៍ច្បាប់នៅតែជាបញ្ហាក្នុងការនាំជនសង្ស័យទៅរកយុត្តិធម៌ ហេតុដូច្នេះអាចរួមចំណែកធ្វើឱ្យមានករណីកើតឡើងកាន់តែច្រើនថែមទៀត។

ក្នុងរយៈពេលនេះ ក៏មានករណីជួញដូរ៧ករណីត្រូវបានរាយការណ៍ដែរ ដែលបណ្ដាលឱ្យមានជនរងគ្រោះជាស្ត្រីសរុប១៥នាក់។ ចំនួននេះមានការកើនឡើងយ៉ាងច្រើន បើប្រៀបធៀបនឹងឆ្នាំកន្លងទៅដែលមានតែ៣ករណីដែលបានរាយការណ៍។ ៧នាក់ក្នុងចំណោមក្មេងស្រីទាំង១៥នាក់ត្រូវបានអះអាងជាជនជាតិខ្មែរ ឬវៀតណាម ជនរងគ្រោះម្នាក់ត្រូវបានដឹងថាត្រូវបានជួញដូរពីប្រទេសវៀតណាម ហើយជនរងគ្រោះនៅគ្រប់ករណីដែលបានរាយការណ៍ទាំងអស់គឺជាអនីតិជន។ ជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះទាំងអស់មកពីរាជធានីភ្នំពេញ ម្នាក់មកពីខេត្តកណ្ដាល ម្នាក់មកពីខេត្តតាកែវ និងម្នាក់មកពីខេត្តសៀមរាប។ ជនរងគ្រោះទាំងអស់ត្រូវបានជួញដូរក្នុងប្រទេសកម្ពុជា ដែលមានរាជធានីភ្នំពេញជាតំបន់គោលដៅ លើកលែងតែករណី២ប៉ុណ្ណោះដែលជនរងគ្រោះត្រូវបានជួញដូរនៅក្នុងខេត្តកណ្ដាល ឬខេត្តសៀមរាប។ ករណីទាំងអស់នេះមានពាក់ព័ន្ធនឹងជនសង្ស័យសរុប១៨នាក់ ដែល១០នាក់ជាបុរស និង៨នាក់ជាស្ត្រី។ ជនសង្ស័យក៏មានសញ្ជាតិជា កម្ពុជា ឬវៀតណាមដែរ។ មាន២ករណី ជនសង្ស័យត្រូវបានអះអាងថាជាម្ដាយជនរងគ្រោះ ប៉ុន្តែទំនាក់ទំនងរវាងជនសង្ស័យ និងជនរងគ្រោះក្នុង៥ករណីផ្សេងទៀតមិនត្រូវបានដឹងទេ។ ក្នុងចំណោមជនសង្ស័យទាំង១៨នាក់ ១៧នាក់ត្រូវបានចាប់ខ្លួន និងម្នាក់បានគេចខ្លួន។ ៦ករណីត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ និង១ ករណីកំពុងស្ថិតក្រោមការស៊ើបអង្កេតរបស់ប៉ូលីស។

ក្នុង៦ខែដើមឆ្នាំ២០១០នេះ ក៏មានករណីអំពើអាសជាមួយកុមារ៨ករណីផងដែរ។ ១ករណីមានពាក់ព័ន្ធជនសង្ស័យ លើសពីម្នាក់ ដែលពួកគេរំលោភបំពានក្មេងស្រីកម្ពុជាអាយុ៦ឆ្នាំម្នាក់ និង៣ករណីមានជនរងគ្រោះលើសពីម្នាក់។ ៣ករណីបានកើតឡើងនៅខេត្តព្រះសីហនុ ១ករណីនៅខេត្តសៀមរាប ១ករណីខេត្តតាកែវ ១ករណីនៅខេត្តកណ្ដាល និង២ករណីនៅរាជធានីភ្នំពេញ។ មានជនសង្ស័យសរុប១០នាក់ ៩នាក់ក្នុងចំណោមពួកគេជា បុរស និងម្នាក់ជាស្ត្រីដែលត្រូវបានរាយការណ៍ថាជាសហចារីនៅក្នុងករណីមួយ។ ជនសង្ស័យត្រូវបាន អះអាងថាជាជនជាតិអាមេរិច២នាក់ ន័រវេស្សម្នាក់ ហូឡង់ម្នាក់ វៀតណាមម្នាក់ និងកម្ពុជា៣នាក់។ ករណី ទាំងនេះមានពាក់ព័ន្ធអ្នករត់ម៉ូតូឌុបម្នាក់ ភ្ញៀវទេសចរណ៍ម្នាក់ នាយកសាលាម្នាក់ អ្នកហៅភ្ញៀវឱ្យ

ស្ត្រីបំរើ ផ្លូវភេទម្នាក់ និងម្នាក់មិនមានការងារធ្វើ។ អាយុរបស់ពួកគេមានពី២៥ឆ្នាំទៅ៦៥ឆ្នាំ។ ជនរងគ្រោះភាគច្រើន មានភេទប្រុស ដែលពួកគេស្ទើរតែទាំងអស់ជាក្មេងអនាថា និងម្នាក់ត្រូវបានអះអាងថាជាក្មេងវត្ត។ មានជនរងគ្រោះសរុប១៦នាក់ពាក់ព័ន្ធក្នុងករណីទាំងនេះ ដែល១២នាក់ជាភេទប្រុស និង៤នាក់ភេទស្រី។ ជនរងគ្រោះទាំងអស់ជាអនីតិជន និងអាយុតិចបំផុតគឺ៦ឆ្នាំ។ ៨នាក់ក្នុងចំណោមជនសង្ស័យទាំងអស់ត្រូវបាន ចាប់ខ្លួន និង២នាក់បានគេចខ្លួន។ ក្នុងពេលនៃការសរសេរវិភាគនេះ ករណីទាំង៨ត្រូវបានបំពេញសំណុំរឿងបញ្ជូនទៅតុលាការ។

អ៊ិកផាតកម្ពុជាសន្និដ្ឋានថា ករណីរំលោភសេពសន្ថវៈ និងការជួញដូរនៅក្នុងប្រទេសកម្ពុជាស្ថិតក្នុងកម្រិតខ្ពស់គួរឱ្យបារម្ភ។ ជនរងគ្រោះភាគច្រើនជាអនីតិជន ហើយជារឿយៗ ជនសង្ស័យពាក់ព័ន្ធក្នុងករណីទាំងនេះជាអ្នកស្គាល់គ្នានឹងកុមារ ជាពិសេសក្នុងករណីរំលោភសេពសន្ថវៈ។ ការកាត់ទោសមានចំនួនតិចគួរឱ្យសោកស្តាយ ដែលនាំឱ្យបញ្ហានេះរឹតតែធ្ងន់ធ្ងរឡើង។ អ៊ិកផាតកម្ពុជាសូមអំពាវនាវដល់រដ្ឋាភិបាល និងស្ថាប័នអនុវត្តច្បាប់សូមពង្រឹងនូវដំណើរការប្រព័ន្ធយុត្តិធម៌ដើម្បីធានាថា ជនសង្ស័យត្រូវបានដាក់ឱ្យទទួលខុសត្រូវ ហើយជនរងគ្រោះត្រូវបានផ្តល់សំណង។ បញ្ហានេះតម្រូវឱ្យមានវិធីសាស្ត្ររួមគ្នា ដែលស្ថាប័នអប់រំ និងមាតាបិតាក៏មានតួនាទីត្រូវបំពេញដែរ ប៉ុន្តែជនសង្ស័យត្រូវតែដឹងថា ពួកគេនឹងត្រូវបានដាក់ទោសទណ្ឌដើម្បីកាត់បន្ថយចំនួនបទល្មើស និងធ្វើឱ្យប្រទេសកម្ពុជាជាប្រទេសកាន់តែមានសុវត្ថិភាពសម្រាប់កុមារ។